# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ ០៩៧/០៧ គ.ជ.ប**

## បទបញ្ជាសំរាប់កម្មវិធីផ្សាយគោលនយោបាយ

អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ និង បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី២ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចេញនូវបទបញ្ជាសំរាប់កម្មវិធីផ្សាយ គោលនយោបាយដូចតទៅ ÷

១-ត្រូវផ្សព្វផ្សាយតែកម្មវិធីនយោបាយរួមរបស់គណបក្សខ្លួនជូនអ្នកបោះឆ្នោត។

២-ត្រូវគោរពពេលវេលាថតវេទិកាតុមូល។

៣-ការមកមិនទាន់ពេលកំណត់ត្រូវបានចាត់ទុកថាសាមី ឬ តំណាងគណបក្សនយោបាយបោះបង់សិទ្ធិរបស់ខ្លួន។

៤-អាចអនុញ្ញាតអោយពាក់សញ្ញាគណបក្សរបស់ខ្លួនបាន តែមិនអនុញ្ញាតប្រើគ្រឿងសំគាល់(insignia) របស់ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល។ល។ និង ។ល។

៥-មិនត្រូវយកវេទិកានេះប្រើប្រាស់ខុសពីប្រធានបទដែលបានផ្តល់ជូនឡើយ។

៦-មិនត្រូវប្រើភាសាជេរប្រមាថ បំភិតបំភ័យ គំរាមកំហែង ហិង្សា ញុះញង់ទៅលើបុគ្គល ឬគណបក្សដទៃឡើយ។

៧-ភ្លើងសញ្ញាសំគាល់ ÷

- ភ្លើងពណ៌លឿងជាសញ្ញាបង្ហាញថានៅសល់ពេលមួយនាទី
- ភ្លើងពណ៌ក្រហមជាសញ្ញាបង្ហាញថាអស់ពេលហើយ។

៨-ក្នុងករណីមានការរំលោភលើចំណុចណាមួយខាងលើ គណៈកម្មការសម្របសម្រួលកម្មវិធីផ្សាយមានសិទ្ធិ ÷

- បញ្ឈប់ការបកស្រាយសំណួរ
- តម្រូវអោយចេញពីវេទិកាក្នុងករណីធ្ងន់ធ្ងរ
- កាត់ចោលខ្លឹមសារផ្ទុយពីច្បាប់ ឬមិនចាក់ផ្សាយជូនទាំងស្រុង
- *ធ្វើលិខិតព្រមានជាសាធារណៈចំពោះសាមីខ្លួន* និងទៅសាមីគណបក្សផ្ទាល់។

ភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៧

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**អ៊ឹម_សូស៊ី**